# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៤៨៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការព័ត៌មាននិងសាធារណមតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការព័ត៌មាននិងសាធារណមតិ ដែលសរសេរជាអក្សរកាត់ថា **គ.ស.ព.ស**. ជាសេនាធិការរបស់រាជរដ្ឋាភិបាលសម្រាប់កិច្ចការព័ត៌មាននិងសាធារណមតិ ដើម្បីការពារសមិទ្ធផល ស្នាដៃ និងកេរ្តិ៍ឈ្មោះរបស់ព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់ គ.ស.ព.ស.

**មាត្រា២ .-**

**គ.ស.ព.ស**. មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ធ្វើកិច្ចការលើការងារពង្រឹងសាធារណមតិ តាមរយៈការតាមដានក្តាប់គ្រប់ស្ថានការណ៍ ឃោសនាពន្យល់ និងការពាររូបភាពវិជ្ជមានរបស់ព្រះរាជាណាចក្រកម្ពុជា

- ការពារអធិបតេយ្យជាតិ ផ្សព្វផ្សាយសមិទ្ធផលរបស់រាជរដ្ឋាភិបាល និងកសាងរូបភាពវិជ្ជមាននិងលើកកម្ពស់កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជាទាំងក្នុងស្រុកនិងលើឆាកអន្តរជាតិ
- ជំរុញប្រសិទ្ធភាពការងារឆ្លើយតបព័ត៌មានក្លែងក្លាយ តាមរយៈការរៀបចំយន្តការឆ្លើយតបឱ្យទាន់ពេលវេលាជាប្រព័ន្ធតួអង្គតែមួយ និងបង្កើនសមត្ថភាពយុទ្ធសាស្ត្របែបឌីជីថល
- ផ្តួចផ្តើមគំនិតលើការផលិតខ្លឹមសារគ្រប់ប្រភេទសម្រាប់ពង្រឹងសាធារណមតិ
- សហការជាមួយបណ្តាញផ្សព្វផ្សាយដើម្បីចែករំលែកខ្លឹមសារនិងផ្សព្វផ្សាយបន្ត
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **គ.ស.ព.ស**. ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣
## សមាសភាពរបស់ គ.ស.ព.ស.

**មាត្រា៣ .-**

**គ.ស.ព.ស**. ស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - ទេសរដ្ឋមន្ត្រី ១រូប | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងព័ត៌មាន | អនុប្រធានទី១ |
| - ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល | អនុប្រធានអចិន្ត្រៃយ៍ |
| - ប្រធានអង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស | អនុប្រធាន |
| - តំណាងខុទ្ទកាល័យនាយករដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| - អ្នកនាំពាក្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - អ្នកនាំពាក្យក្រសួងការពារជាតិ ១រូប | សមាជិក |
| - អ្នកនាំពាក្យក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| - អ្នកនាំពាក្យក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - អ្នកនាំពាក្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - ប្រធានលេខាធិការដ្ឋាននៃ **គ.ស.ព.ស**. | សមាជិក។ |

**គ.ស.ព.ស**. អាចបន្ថែមសមាសភាពជាអនុប្រធាននិងសមាជិកតាមការចាំបាច់។

សមាសភាពជាក់ស្តែងរបស់ **គ.ស.ព.ស**. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ស.ព.ស.

**មាត្រា៤ .-**

ប្រធាន **គ.ស.ព.ស**. ដឹកនាំកិច្ចការទូទៅរបស់ **គ.ស.ព.ស**.។ នៅពេលដែលប្រធាន **គ.ស.ព.ស**. អវត្តមានឬមានករណីចាំបាច់ ប្រធាន **គ.ស.ព.ស**. អាចប្រគល់សិទ្ធិជូនអនុប្រធានទី១ឱ្យទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ **គ.ស.ព.ស**. ក្នុងឋានៈជាប្រធានស្តីទី រហូតដល់មានវត្តមានប្រធាន **គ.ស.ព.ស**.។

អនុប្រធានទី១ អនុប្រធានអចិន្ត្រៃយ៍ និងអនុប្រធាន **គ.ស.ព.ស**. អនុវត្តការងារតាមការកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.ព.ស**. ។

**មាត្រា៥ .-**

អនុប្រធាននិងសមាជិកនៃ **គ.ស.ព.ស**. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ស.ព.ស**.។ ក្នុងករណីប្រធាន **គ.ស.ព.ស**. អវត្តមានឬមានធុរៈ ប្រធាន **គ.ស.ព.ស**. អាចប្រគល់សិទ្ធិជូនអនុប្រធានទី១ ឬអនុប្រធានអចិន្ត្រៃយ៍ ឬអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់ **គ.ស.ព.ស**. ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ស.ព.ស**.។

**មាត្រា៦ .-**

**គ.ស.ព.ស**. អាចអញ្ជើញអ្នកនាំពាក្យក្រសួង ស្ថាប័ននិងអ្នកនាំពាក្យរដ្ឋបាលរាជធានី ខេត្ត ចូលរួមប្រជុំពិគ្រោះយោបល់និងបំភ្លឺរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន និងការងារចាំបាច់នានា ដែលត្រូវទទួលអនុវត្ត។

**មាត្រា៧ .-**

**គ.ស.ព.ស**. អាចមានទីប្រឹក្សានិងជំនួយការមួយចំនួនតាមការចាំបាច់ អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទីប្រឹក្សា **គ.ស.ព.ស**. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងជំនួយការ **គ.ស.ព.ស**. ត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា៨ .-**

**គ.ស.ព.ស**. មានក្រុមការងារយុទ្ធសាស្ត្រ ដើម្បីជួយតម្រង់ទិសដៅការងារលើខ្លឹមសារជាយុទ្ធសាស្ត្រក្នុងកិច្ចការព័ត៌មាននិងសតិអារម្មណ៍ ដើម្បីឆ្លើយតបនិងផ្សារភ្ជាប់កិច្ចការប្រតិបត្តិរបស់រាជរដ្ឋាភិបាល។

ក្រុមការងារយុទ្ធសាស្ត្រនៃ **គ.ស.ព.ស**. មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - ប្រធាន **គ.ស.ព.ស**. | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងព័ត៌មាន | អនុប្រធាន |
| - ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល | សមាជិក |
| - ប្រធានអង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស | សមាជិក |
| - តំណាងខុទ្ទកាល័យនាយករដ្ឋមន្ត្រី ១រូប | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - តំណាងក្រសួងការពារជាតិ ១រូប | សមាជិក |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - តំណាងក្រសួងយុត្តិធម៌ ១រូប | សមាជិក។ |

សមាសភាពជាក់ស្តែងរបស់ក្រុមការងារយុទ្ធសាស្ត្ររបស់ **គ.ស.ព.ស**. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ឬដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីតាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី។

**មាត្រា៩ ._**

**គ.ស.ព.ស.** មានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល និងអង្គភាពព័ត៌មាននិងប្រតិកម្មរហ័សជាសេនាធិការ និងគាំទ្រដោយប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋនិងឯកជន។

**មាត្រា១០ ._**

**គ.ស.ព.ស.** មានលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី។

លេខាធិការដ្ឋាននៃ **គ.ស.ព.ស.** ដឹកនាំដោយប្រធាន១(មួយ)រូប មានអនុប្រធាននិងសមាជិកមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋាននៃ **គ.ស.ព.ស.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។ ក្នុងករណីចាំបាច់ លេខាធិការដ្ឋាននៃ **គ.ស.ព.ស.** អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យជួយការងារ។

**មាត្រា១១ ._**

លេខាធិការដ្ឋាននៃ **គ.ស.ព.ស.** មានភារកិច្ចដូចតទៅ៖

- សម្របសម្រួលនិងទទួលបន្ទុកការងារទូទៅប្រចាំថ្ងៃរបស់ **គ.ស.ព.ស.**
- រៀបចំយុទ្ធសាស្ត្រព័ត៌មានដើម្បីគាំទ្រដល់ការតាមដាន និងផ្សព្វផ្សាយព័ត៌មានឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព
- គាំទ្រយន្តការឆ្លើយតបទៅនឹងព័ត៌មានក្លែងក្លាយឱ្យទាន់ពេលវេលានិងជាប្រព័ន្ធ
- រៀបចំ និងពង្រឹងបណ្តាញបញ្ជូននិងចែកចាយព័ត៌មានទាំងក្នុងនិងក្រៅស្រុក
- គ្រប់គ្រងនិងដឹកនាំការងាររបស់លេខាធិការដ្ឋាន
- ទទួលបន្ទុករៀបចំ គ្រប់គ្រង និងចាត់ចែងថវិការបស់ **គ.ស.ព.ស.**
- ទទួលបន្ទុករៀបចំ គ្រប់គ្រង និងចាត់ចែងសម្ភារៈ បរិក្ខាររបស់ **គ.ស.ព.ស.**
- គ្រប់គ្រងឯកសារចេញចូល
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំស្តីពីសកម្មភាពរបស់ **គ.ស.ព.ស.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ស.ព.ស.**។

**មាត្រា១២ ._**

**គ.ស.ព.ស.** និងលេខាធិការដ្ឋាននៃ **គ.ស.ព.ស.** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ស.ព.ស.

**មាត្រា១៣ ._**

**គ.ស.ព.ស.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**គ.ស.ព.ស.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននូវមូលនិធិដែលបានមកពីដៃគូអភិវឌ្ឍនិងប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

# ជំពូកទី៦
# អវសានប្បញ្ញត្តិ

**មាត្រា១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣៤ ខែ ស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ